ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ

វិទ្យាស្ថានពហុបច្ចេកទេសព្រះកុសុមៈ

# សេចក្តីជូនដំណឹង

## ស្តីពីការជ្រើសរើសសិស្ស-និស្សិតអាហារូបករណ៍និងបង់ថ្លៃអោយចូលរៀន នៅវិទ្យាស្ថានពហុបច្ចេកទេសព្រះកុសុមៈសំរាប់ឆ្នាំសិក្សា ២០១១-២០១២

**វិទ្យាស្ថានពហុបច្ចេកទេសព្រះកុសុមៈ** សូមជូនដំណឹងដល់សាធារណៈជនទាំងអស់ អោយបានជ្រាបថា : នៅក្នុងឆ្នាំសិក្សា ២០១១-២០១២ ខាងមុខនេះ វិទ្យាស្ថាននឹងមានធ្វើការជ្រើសរើស សិស្ស-និស្សិតទាំងពីរភេទ ឱ្យចូលរៀនផ្នែកបច្ចេកវិទ្យាដែលមានថ្នាក់**បរិញ្ញាប័ត្រជាន់ខ្ពស់បច្ចេកវិទ្យា(អនុបណ្ឌិត)**ថ្នាក់**បរិញ្ញាប័ត្របច្ចេកវិទ្យា**ថ្នាក់ **ជាន់ខ្ពស់បច្ចេកទេស (បរិញ្ញាប័ត្ររង)** ថ្នាក់ **បច្ចេកទេស និង វិជ្ជាជីវៈ** និង ផ្នែកពាណិជ្ជសាស្ត្រ ថ្នាក់ **បរិញ្ញាប័ត្រជាន់ខ្ពស់ពាណិជ្ជសាស្ត្រ (អនុបណ្ឌិត)** ថ្នាក់ **បរិញ្ញាប័ត្រពាណិជ្ជសាស្ត្រ** និងថ្នាក់ **ជាន់ខ្ពស់ពាណិជ្ជសាស្ត្រ(បរិញ្ញាប័ត្ររង)** ទាំងថ្នាក់ អាហារូបករណ៍ និងទាំង ថ្នាក់សិក្សាបង់ថ្លៃ តាមលក្ខខ័ណ្ឌដូចខាងក្រោមនេះ :

**I <u>កំរិតសញ្ញាប័ត្រ មុខជំនាញ រយៈពេលសិក្សា និង ចំនួនសិស្ស-និស្សិតដែលត្រូវជ្រើសរើស</u>**

### ១-ផ្នែកបច្ចេកវិទ្យា (Technology)

| ល.រ | កំរិតសញ្ញាប័ត្រ រយៈពេលសិក្សា | វិស្វកម្មអគ្គិសនី | | វិស្វកម្មសំណង់ស៊ីវិល | | វិស្វកម្មអេឡិចត្រូនិច | | បច្ចេកវិទ្យាព័ត៌មាន |
|---|---|---|---|---|---|---|---|---|
| | | អាហារូបករណ៍ | បង់ថ្លៃ | អាហារូបករណ៍ | បង់ថ្លៃ | អាហារូបករណ៍ | បង់ថ្លៃ | បង់ថ្លៃ |
| ១ | អនុបណ្ឌិត (២ឆ្នាំ) | | ៣០នាក់ | | ៣០នាក់ | | ៣០នាក់ | |
| ២ | បរិញ្ញាប័ត្រ (៤ឆ្នាំកន្លះ) | ៤០នាក់ | ៤០នាក់ | ៤០នាក់ | ៤០នាក់ | ៤០នាក់ | ៤០នាក់ | ៤០នាក់ |
| ៣ | បរិញ្ញាប័ត្ររង (២ឆ្នាំ) | ៤០នាក់ | ៤០នាក់ | ៤០នាក់ | ៤០នាក់ | ៤០នាក់ | ៤០នាក់ | ៤០នាក់ |
| ៤ | បច្ចេកទេសនិងវិជ្ជាជីវៈ(៣ឆ្នាំ) | ៤០នាក់ | | ៤០នាក់ | | ៤០នាក់ | | |

### ២-ផ្នែកពាណិជ្ជសាស្ត្រ (Business)

| ល.រ | កំរិតសញ្ញាប័ត្រ រយៈពេលសិក្សា | គណនេយ្យ-ហិរញ្ញវត្ថុ | | គ្រប់គ្រង | | ម៉ាឃីតធីង | |
|---|---|---|---|---|---|---|---|
| | | អាហារូបករណ៍ | បង់ថ្លៃ | អាហារូបករណ៍ | បង់ថ្លៃ | អាហារូបករណ៍ | បង់ថ្លៃ |
| ១ | អនុបណ្ឌិត (២ឆ្នាំ) | | ៣០នាក់ | | ៣០នាក់ | | ៣០នាក់ |
| ២ | បរិញ្ញាប័ត្រ (៤ឆ្នាំ) | ៤០នាក់ | ៤០នាក់ | ៤០នាក់ | ៤០នាក់ | ៤០នាក់ | ៤០នាក់ |
| ៣ | បរិញ្ញាប័ត្ររង (២ឆ្នាំ) | ៤០នាក់ | ៤០នាក់ | ៤០នាក់ | ៤០នាក់ | ៤០នាក់ | ៤០នាក់ |

## II លក្ខខណ្ឌនៃការជ្រើសរើស

### ១-កំរិតវប្បធម៌

ក-សំរាប់ថ្នាក់បរិញ្ញាប័ត្រជាន់ខ្ពស់បច្ចេកវិទ្យា និងបរិញ្ញាប័ត្រជាន់ខ្ពស់ពាណិជ្ជសាស្ត្រ (អនុបណ្ឌិត) សំរាប់អ្នកមានបរិញ្ញាប័ត្របច្ចេកវិទ្យា និងអ្នកមានបរិញ្ញាប័ត្រពាណិជ្ជសាស្ត្រ ។

ខ-សំរាប់ថ្នាក់បរិញ្ញាប័ត្របច្ចេកវិទ្យា បរិញ្ញាប័ត្រពាណិជ្ជសាស្ត្រ បរិញ្ញាប័ត្ររងបច្ចេកវិទ្យា និងពាណិជ្ជសាស្ត្រ បេក្ខជនត្រូវមាន **ព្រឹត្តិប័ត្រលទ្ធផលប្រលងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ** (សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិឆ្នាំ ២០០៩ ២០១០ និង២០១១ សំរាប់ជ្រើសរើសអាហារូបករណ៍) ។

គ-សំរាប់ថ្នាក់បច្ចេកទេសនិងវិជ្ជាជីវៈ បេក្ខជនត្រូវមានចំណេះដឹងយ៉ាងទាបបំផុតរៀនចប់ថ្នាក់ទី ៩ចំណេះទូទៅ ។

**២-អាយុ** : ពី ១៥-៣៤ ឆ្នាំ ។

**៣-កាយសម្បទា** : ត្រូវមានកាយសម្បទា និង សុខភាពល្អ ។

**៤-ការជ្រើសរើស** : ក-សំរាប់ថ្នាក់បរិញ្ញាប័ត្របច្ចេកវិទ្យា ថ្នាក់បរិញ្ញាប័ត្រពាណិជ្ជសាស្ត្រ និងបរិញ្ញាប័ត្ររងបច្ចេកវិទ្យា និងពាណិជ្ជសាស្ត្រ បេក្ខជន ពុំមានធ្វើការប្រឡងប្រជែងទេ គឺធ្វើការជ្រើសរើសដោយផ្អែកលើព្រឹត្តិប័ត្រលទ្ធផលប្រលងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ ។

ខ-សំរាប់ថ្នាក់បច្ចេកទេសនិងវិជ្ជាជីវៈ ត្រូវធ្វើការប្រឡងប្រជែងតាមកម្មវិធីថ្នាក់ទី៩ ចំណេះទូទៅ លើមុខវិជ្ជាមូលដ្ឋាន ៣ ដូចខាងក្រោម :

- វប្បធម៌ទូទៅ រយៈពេល ១ ម៉ោង
- រូបវិទ្យា រយៈពេល ១ ម៉ោង
- គណិតវិទ្យា រយៈពេល ១ ម៉ោង

## III សំណុំលិខិតដែលត្រូវបំពេញ

១-ពាក្យសុំប្រឡង (មានបិទតែមប្រិ៍ ៦០០រៀល) ........ ០១ ច្បាប់ (មានគំរូ)

២-ក-សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ ឬ ព្រឹត្តិប័ត្រលទ្ធផលប្រលងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ ........ ០១ ច្បាប់

ខ-លិខិតបញ្ជាក់បានរៀនចប់ថ្នាក់ទី ៩ ឬ សញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ ឬ សញ្ញាប័ត្រដែលមានតំលៃស្មើ (ចំពោះថ្នាក់បច្ចេកទេស និងវិជ្ជាជីវៈ) ........ ០១ ច្បាប់

៣-ជីវប្រវត្តិសង្ខេប ........ ០២ ច្បាប់

៤-រូបថតថ្មី ថតចំពីមុខ គ្មានពាក់វ៉ែនតា (៤x៦) ........ ០៣ សន្លឹក

៥-បង្កាន់ដៃបង់ប្រាក់ "សុំសិទ្ធប្រឡង" ........ ០១ ច្បាប់

៦-បង្កាន់ដៃទទួលពាក្យសុំប្រឡង ........ ០១ ច្បាប់

៧-លិខិតបញ្ជាក់កាយសម្បទាផ្តល់ក្រោយពេលប្រឡង ........ ០១ ច្បាប់

ចំពោះបេក្ខជនដែលមានស្ថានភាពក្រីក្រ អ្នកនៅតំបន់ដាច់ស្រយាល និងស្ត្រីភេទ មានអទិភាពទទួលអាហារូបករណ៍ចំនួន ១០% ក្នុងផ្នែកនិមួយៗ ។ ដោយឡែក អ្នកដែលមានស្ថានភាពក្រីក្រ ត្រូវមានឯកសារ ០២ច្បាប់ ភ្ជាប់មកជាមួយថែមទៀត :

ក-សេចក្តីបញ្ជាក់ត្រឹមត្រូវពីរដ្ឋអំណាច ថ្នាក់ឃុំ ឬ សង្កាត់ អំពីភាពក្រីក្រ និង អាស័យដ្ឋានដែលបានរស់នៅ ។

ខ-ប័ណ្ណគ្រួសារថតចំលងតាមផ្លូវច្បាប់ ០១ ច្បាប់ ។

**IV- ការទទួលពាក្យ** : ចាប់ពីការផ្សាយដំណឹងនេះតទៅរហូតដល់ **ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០១១** វេលាម៉ោង ១៧:០០ ជាកំហិត ។

**V- កន្លែងទទួលពាក្យ** : ការិយាល័យទំនាក់ទំនងចុះឈ្មោះចូលរៀននៃវិទ្យាស្ថានពហុបច្ចេកទេសព្រះកុសុមៈ ។

**VI- កាលបរិច្ឆេទជ្រើសរើស** : ក/ **ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១១** ( សំរាប់ថ្នាក់បរិញ្ញាប័ត្របច្ចេកវិទ្យា ថ្នាក់បរិញ្ញាប័ត្រពាណិជ្ជសាស្ត្រ និងបរិញ្ញាប័ត្ររងបច្ចេកវិទ្យា និងពាណិជ្ជសាស្ត្រ ) ។

: ខ/ ធ្វើការប្រឡងប្រជែងនៅ **ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១១** (សំរាប់ថ្នាក់បច្ចេកទេស និងវិជ្ជាជីវៈ) ។

**VII-មណ្ឌលប្រឡង** : នៅវិទ្យាស្ថានពហុបច្ចេកទេសព្រះកុសុមៈ ។

ចំពោះព័ត៌មានលំអិតផ្សេងៗទៀត សូមអញ្ជើញទាក់ទងការិយាល័យអប់រំ នៃវិទ្យាស្ថានពហុបច្ចេកទេសព្រះកុសុមៈ ដែលមានទីតាំងស្ថិតនៅតាមបណ្តោយមហាវិថីសហព័ន្ធរុស្ស៊ី ច្រកចូលខាងកើតក្រុមហ៊ុន Metfone និងវត្តទឹកថ្លា ចំងាយ ១០៨ម៉ែត្រ សង្កាត់ទឹកថ្លា ខ័ណ្ឌសែនសុខ រាជធានីភ្នំពេញ រាល់ម៉ោងធ្វើការ ។

ទូរស័ព្ទលេខ : ០១២ ៨២៦ ៤០៤ . ០១១ ៧៦០ ០០០ . ០១៦ ៨៤៤ ៤០៧ . ០១២ ៦៩៥ ៦៤៤ . ០៩៧ ៩ ៩៧២ ៨០០ . ០៩៧ ២ ១៩០ ០០២ . ០១៧ ៣៩៥ ២៨៣ ។

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១១

**នាយកវិទ្យាស្ថាន**

បណ្ឌិត.**ហែម_ចន្ថា**

**ចម្លងជូន**

- អគ្គនាយកដ្ឋាន អ.ប.វ
- នាយកដ្ឋាន ត.ក.អ.ប.វ
- អង្គភាពក្រោមឱវាទក្រសួង ក.ប.វ
  "ដើម្បីជ្រាបជាព័ត៌មាន និង ផ្សព្វផ្សាយ"
- ឯកសារ
- កាលប្បវត្តិ